ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ.០១៥.......សហវ

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរំលឹកការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនលោក លោកស្រី ដែលជាម្ចាស់យានយន្តគ្រប់ប្រភេទ មេត្តាជ្រាបថា ចាប់ពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ រហូតមកទល់ពេលនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្កេតឃើញថា មានម្ចាស់យានយន្តជាច្រើនបានអញ្ជើញមកបង់ពន្ធតាមសេចក្តីជូនដំណឹងលេខ ០០៧ សហវ.អពដ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ទន្ទឹមនឹងនេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏សង្កេតឃើញដែរថាមានបណ្ណបង់ពន្ធឆ្នាំចាស់២០១០ ដាក់ភ្ជាប់ជាមួយឯកសារប្រកាសបង់ពន្ធមធ្យោបាយលើរថយន្តមួយចំនួន ជាឯកសារក្លែងក្លាយ ។ ភ្នាក់ងារពន្ធដារ មានសមត្ថកិច្ចប្រមូលពន្ធលើមធ្យោបាយឆ្នាំ២០១១នេះ បានឃាត់ និងដកទុកឯកសារក្លែងក្លាយទាំងនេះ សម្រាប់ធ្វើការបន្តស្រាវជ្រាវ និងបានធ្វើការកំណត់ឲ្យបង់ពន្ធឆ្នាំ២០១០ ឡើងវិញ ព្រមទាំងអនុវត្តការផាកពិន័យតាមច្បាប់កំណត់ថែមទៀត ទើបអនុញ្ញាតឲ្យបង់ពន្ធមធ្យោបាយឆ្នាំថ្មី២០១១ ។

ក្នុងស្មារតីរួមចំណែកទប់ស្កាត់ការក្លែងបន្លំបណ្ណបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមស្វាគមន៍នូវរាល់កិច្ចសហការក្នុងការផ្តល់ព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងបទល្មើសក្លែងបន្លំបណ្ណបង់ពន្ធខាងលើនេះ ដើម្បីយកជនដែលប្រព្រឹត្តបទល្មើស មកផ្តន្ទាទោសតាមច្បាប់ ។

ទន្ទឹមនឹងនេះ ដើម្បីចៀសវាងការទិញបណ្ណបង់ពន្ធរថយន្តក្លែងក្លាយ និងការថ្នាំងថ្នាក់ទាំងឡាយដែលកើតមានឡើងក្នុងពេលត្រួតពិនិត្យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមម្ចាស់យានយន្តទាំងអស់មេត្តាអញ្ជើញមកបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ នៅតាមកន្លែង ទីតាំងដែលកំណត់ដោយរដ្ឋបាលដែនដី រាជធានី-ខេត្ត និងឲ្យបានចប់សព្វគ្រប់ត្រឹមថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ខាងមុខនេះ ព្រោះចាប់ពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ តទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យដោយផាកពិន័យបន្ថែមលើប្រាក់ពន្ធស្មើនឹង ១០០ ភាគរយ នៃប្រាក់ពន្ធត្រូវបង់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រី ជាម្ចាស់យានយន្តមានស្មារតីគោរពច្បាប់ និងអញ្ជើញមកបង់ពន្ធតាមកាលកំណត់ជាពុំខាន ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798